ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខ : ១៧៦/១៦

# កំណត់ហេតុកិច្ចប្រជុំ

## ស្តីពីការត្រៀមរៀបចំសិក្ខាសាលាថ្នាក់ជាតិ ស្តីពីការពង្រឹងការអនុវត្តច្បាប់ និងប្រព័ន្ធយុត្តិធម៌ការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស

ឆ្នាំពីរពាន់ដប់ប្រាំមួយ ខែតុលា ថ្ងៃទីដប់ប្រាំបួន វេលាម៉ោងប្រាំបួនព្រឹក នៅសាលប្រជុំអគ្គលេខាធិការដ្ឋានគ.ជ.ប.ជ មានបើកកិច្ចប្រជុំពិភាក្សាស្តីពីការត្រៀមរៀបចំសិក្ខាសាលាថ្នាក់ជាតិ ស្តីពីការពង្រឹងការអនុវត្តច្បាប់ និងប្រព័ន្ធយុត្តិធម៌ការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស ក្រោមអធិបតីភាពលោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ ។

សមាសភាពចូលរួមកិច្ចប្រជុំរួមមានតំណាង អគ្គលេខាធិការដ្ឋានគ.ជ.ប.ជ អគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងយុត្តិធម៌ ក្រសួងការងារ ក្រសួងសង្គមកិច្ច និងអង្គការ Cambodia ACTs ។

គោលបំណងនៃកិច្ចប្រជុំគឺ ដើម្បីពិភាក្សានូវចំណុចពាសំខាន់សម្រាប់ជាប្រធានបទនៃសិក្ខាសាលារួមមានការផ្តល់សំណងដល់ជនរងគ្រោះ នីតិវិធីជំនួយផ្នែកច្បាប់ និងការផ្តល់ទីកន្លែងសម្រាប់ប្រព្រឹត្តអំពើជួញដូរមនុស្ស ព្រមទាំងរកនូវចំណុចសំខាន់ៗ បន្ថែមទៀតសម្រាប់ដាក់ចូលក្នុងសិក្ខាសាលាថ្នាក់ជាតិ ដែលនឹងប្រព្រឹត្តទៅក្នុងពេលឆាប់ៗនេះ ។

បន្ទាប់ពីបានប្រជុំពិភាក្សាចូលរួមយោបល់ពីគ្រប់ស្ថាប័ន-អង្គភាពរួចមក អង្គប្រជុំទទួលបានលទ្ធផលដូចខាងក្រោម ៖

១.ការផ្តល់សំណងដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស

- បញ្ហានៅត្រង់ថា កន្លងមកការផ្តន្ទាទោស និងសំណងមិនទាន់អនុវត្តបានល្អប្រសើរនៅឡើយ ដូចនេះត្រូវរិះរកនូវដំណោះស្រាយឲ្យបានប្រសើរសម្រាប់ជនរងគ្រោះ ។
- ជនរងគ្រោះតែងតែរអ៊ូរទាំថាសំណងដែលសាលក្រមតុលាការបានកំណត់មិនដែលបានអនុវត្តឲ្យបានសមស្របឡើយ ។
- **ឯកឧត្តម ពេញ វិបុល ព្រះរាជអាជ្ញា និងជាអគ្គនាយករងនៃក្រសួងយុត្តិធម៌** បានលើកឡើងថា នៅពេលចេញសាលក្រមស្ថាពរ ជនរងគ្រោះត្រូវដាក់ពាក្យស្នើសុំទៅតុលាការដើម្បីឲ្យអនុវត្តការផ្តល់សំណងដោយបង្ខំ ឬដោយស្ម័គ្រចិត្ត (បើមិនមានការស្នើសុំនោះមិនមានអ្នកអនុវត្តទេ កន្លងមកជនរងគ្រោះដែលមិនបានទទួលសំណងមកពីមិនបានដាក់ពាក្យស្នើសុំអនុវត្ត)។ ក្នុងករណីមិនសងដើមបណ្តឹងអាចដាក់ពាក្យប្តឹងទៅតុលាការ ស្នើសុំចុះកត់ត្រាទ្រព្យសម្បត្តិលក់ ឡៃឡុង ឬបើមិនសងអាចនឹងត្រូវដាក់ទោសបន្ថែម ។

- **លោកជំទាវ ឧត្តមសេនីយ៍ឯក យក់ សុខា អគ្គស្នងការរងនគរបាលជាតិ** បានលើកឡើងថា នាយកដ្ឋានសន្តិសុខផ្ទៃក្នុងអាចត្រួតពិនិត្យហិរញ្ញវត្ថុរបស់ជនល្មើសនៅធនាគារបាន និងធ្វើការបង្កកដើម្បីដោះស្រាយ ។

២. **នីតិវិធីជំនួយផ្នែកច្បាប់ក្នុងរឿងក្តីព្រហ្មទណ្ឌជួញដូរមនុស្ស**

- បញ្ហានោះគឺ ករណីជនល្មើសនៅក្រៅប្រទេស និងការបញ្ជូនជនរងគ្រោះត្រឡប់មកវិញតាមរយៈអាជ្ញាធរកណ្តាល ដែលតាំងពីឆ្នាំ២០១១មកមិនទាន់មានករណីដាក់ទៅអាជ្ញាធរកណ្តាលទេ(អាជ្ញាធរកណ្តាលមាននៅ១០ប្រទេសក្នុងអាស៊ាន ដែលកម្ពុជាមានសន្ធិសញ្ញាជាមួយ) ។ កន្លងមកមានការពិបាកក្នុងការស្វែងរកភស្តុតាង និងសាក្សីនៅក្រៅប្រទេស ដែលវានៅក្រោមយុត្តាធិការរបស់អាជ្ញាធរកណ្តាល ។
- គោលបំណងផ្លូវច្បាប់ត្រូវសរសេរឲ្យចំតែម្តង ។
- ត្រូវមើលវិធានជាសកល ទាក់ទងច្បាប់អន្តរជាតិ និងកិច្ចសហប្រតិបត្តិការអន្តរជាតិ ។

៣. **ការផ្តល់ទីកន្លែងសម្រាប់ប្រព្រឹត្តអំពើជួញដូរមនុស្ស**

- កន្លងមកមិនទាន់មានការផ្តន្ទាទោសដាក់លាក់ ក្នុងករណីការផ្តល់ទីកន្លែងសម្រាប់ប្រព្រឹត្តអំពើជួញដូរមនុស្ស ដែលទីកន្លែងទាំងនោះត្រូវបានបិទប៉ុន្មាន ឬពិន័យប៉ុន្មាន គឺមិនបានដឹងច្បាស់នៅឡើយ ។
- ការរឹបអូសទីកន្លែងជាយុត្តាធិការរបស់តុលាការ តែតុលាការពេលខ្លះអនុវត្តផ្ទុយ និងពេលខ្លះទុកចោល ។ មានតែក្រសួងយុត្តិធម៌ទេដែលអាចកែសម្រួលចំណុចខ្វះចន្លោះរបស់តុលាការបាន ។
- ក្រុមការងារអនុវត្តន៍ច្បាប់ដឹងថាបង្ក្រាបបានប៉ុន្មាន បញ្ជូនទៅតុលាការបានប៉ុន្មានករណី គឺមានតែនាយកដ្ឋានប្រឆាំងការជួញដូរមនុស្សដែលដឹង និងត្រូវលើកឡើង ។
- ត្រូវគិតមើលការផ្តល់ទីតាំងកម្រិតណាដែលអាចធ្វើការចោទប្រកាន់ និងផ្តន្ទាទោស ។
- ចង់ឲ្យក្រសួងយុត្តិធម៌ផ្តល់ទិន្នន័យអំពីការកាត់ទោស និងកន្លែងទីតាំងបានបិទ តើអាចដាក់ចូលក្នុងអង្គសិក្ខាសាលាបានទេ ។
- ត្រូវលើកយកបញ្ហា និងវិវាទការងារមកនិយាយផងដែរ ។
- ត្រូវលើកយកករណីជាក់ស្តែងមកនិយាយតែម្តង ។

លោកជំទាវអនុប្រធានអចិន្ត្រៃយ៍ បានមានប្រសាសន៍ណែនាំអំពីការងារសំខាន់ៗចំនួន ៤ ដែលត្រូវធ្វើដើម្បីត្រៀមសម្រាប់សិក្ខាសាលាថ្នាក់ជាតិ រួមមាន៖

១.សូមត្រៀមរបាយការណ៍បង្ក្រាប និងសង្គ្រោះ (ត្រូវការទិន្នន័យកន្លងមក ចំណុចប្រឈម វិធានការ និងកិច្ចសហប្រតិបត្តិការថាតើថយក្រោយ ឬទៅមុខ) ។

២.សូមផ្តល់របាយការណ៍ផ្តន្ទាទោស និងនីតិវិធីនៃការផ្តន្ទាទោស ។ សូមឲ្យព្រះរាជអាជ្ញាតាមខេត្ត ឬក្រសួងយុត្តិធម៌និយាយរឿងនេះ ។

៣.សូមឲ្យមានរបាយការណ៍ពីក្រសួងការងារ ទាក់ទងនឹងការដោះស្រាយវិវាទការងារ និងពាក់ព័ន្ធការកេងប្រវ័ញ្ចកម្លាំងពលកម្ម ។

៤.សូមផ្តល់ការគាំទ្រផ្នែកច្បាប់ដល់ជនរងគ្រោះ ដែលមានពាក់ព័ន្ធនឹងជនរងគ្រោះក្រោមបន្ទុករបស់ក្រសួងសង្គមកិច្ច ។

ជាទីបញ្ចប់ លោកជំទាវបានមានប្រសាសន៍ណែនាំការងារមួយចំនួនបន្ថែមទៀត ដូចខាងក្រោម៖

- ប្រធានបទនៃសិក្ខាសាលាអាចនឹងដាក់ថា "ការពង្រឹង ឬលើកកម្ពស់ កិច្ចសហប្រតិបត្តិការក្នុងការអនុវត្តច្បាប់ និងយុត្តិធម៌" ហើយសិក្ខាសាលាអាចនឹងប្រព្រឹត្តទៅនៅចុងខែវិច្ឆិកា ឆ្នាំ២០១៦នេះ ដែលនឹងអញ្ជើញ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាអធិបតីដ៏ខ្ពង់ខ្ពស់ ។
- ក្រសួង ស្ថាប័ននីមួយៗ ត្រូវរំលេចនូវស្នាដៃរបស់ខ្លួនរួមមាន ទិន្នន័យ លទ្ធផល ឬភាពរីកចម្រើនក្នុងកិច្ចសហការ បញ្ហាប្រឈម វិធានការ និងសំណូមពរ ។ រកនូវចំណុចខ្វះចន្លោះក្នុងកិច្ចសហការគ្នា ថាតើនៅខ្វះនីតិវិធី ឬគោលការណ៍ណែនាំ ។ ត្រូវចាប់ផ្តើមគិតពីឥឡូវ ។
- ក្រសួងសង្គមកិច្ចអាចនិយាយពីការផ្តល់សាក្សីជាជនរងគ្រោះ ។
- ក្រសួងការងារ គួរលើកអំពីមាត្រា និងចំណុចគោលនយោបាយមកនិយាយផង ។
- អង្គការផ្នែកច្បាប់គាំទ្រផ្នែកច្បាប់អាជួបពិភាក្សាគ្នាអំពីលទ្ធផល បញ្ហាប្រឈម និងសំណូមពរ រួចដាក់មកដើម្បីធ្វើការពិភាក្សាថាត្រូវយកចំណុចណាខ្លះ ។
- ជោគជ័យក្នុងការងារនេះគឺផ្តន្ទាទោសជនល្មើស និងរកយុត្តិធម៌ជូនជនរងគ្រោះ ។
- សូមបញ្ចប់របាយការណ៍ឲ្យបានមុនថ្ងៃទី០៧ ខែវិច្ឆកា ព្រោះនឹងជួបប្រជុំគ្នាម្តងទៀតដើម្បីសម្រេចថាតើចំណុចណាត្រូវរំលេច ឬដកចេញ ។

កិច្ចប្រជុំបានបញ្ចប់នៅវេលាម៉ោងដប់ពីរថ្ងៃត្រង់ ថ្ងៃខែឆ្នាំដដែល ក្រោមបរិយាកាសស្និទ្ធស្នាល និងក្នុងស្មារតីទទួលខុសត្រូវខ្ពស់ ។

ភ្នំពេញ ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦

**អ្នកកត់ត្រា**

គោរពជូន លោកជំទាវ

អនុប្រធានអចិន្ត្រៃយ៍ មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ ។

ភ្នំពេញ ថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៦

**ប្រធានលេខាធិការដ្ឋាន**

ឧត្តមសេនីយ៍ត្រី គង់_ពុទ្ធី

បានឃើញ

11/10/2016

ជូ_ប៊ុនអេង

# សមាសភាពចូលរួមកិច្ចប្រជុំ
# ស្តីពីការត្រៀមរៀបចំសិក្ខាសាលាថ្នាក់ជាតិ ស្តីពីការពង្រឹងការអនុវត្តច្បាប់
# និងប្រព័ន្ធយុត្តិធម៌ការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស
# នៅថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៦

| | | | |
|---|---|---|---|
| - លោកជំទាវ | ជូ ប៊ុនអេង | រដ្ឋលេខាធិការ | អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ |
| - លោកជំទាវ | សួស រដ្ឋាវី | អនុរដ្ឋលេខាធិការ | ក្រសួងការងារ |
| - ឯកឧត្តម ឧ.ឯក | ថោង សំអាត | អគ្គលេខាធិការ | គ.ជ.ប.ជ |
| - លោកជំទាវ ឧ.ឯក | យក់ សុខា | អគ្គស្នងការរង | អគ្គស្នងការដ្ឋាននគរបាលជាតិ |
| - ឯកឧត្តម | ពេញ វិបុល | ព្រះរាជអាជ្ញា និងជាអគ្គនាយករង | ក្រសួងយុត្តិធម៌ |
| - ឯកឧត្តម ឧ.ឯក | ស៊ុន រ៉ូ | អគ្គលេខាធិការរង | គ.ជ.ប.ជ |
| - ឯកឧត្តម ឧ.ឯក | យឹម វិរៈ | អគ្គលេខាធិការរង | គ.ជ.ប.ជ |
| - លោកជំទាវ ឧ.ឯក | ប៉ុណ្ណ សំខាន់ | អគ្គលេខាធិការរង | គ.ជ.ប.ជ |
| - ឯកឧត្តម ឧ.ទោ | អ៊ូ ម៉ានីរ៉ា | អគ្គលេខាធិការរង | គ.ជ.ប.ជ |
| - ឧត្តមសេនីយ៍ត្រី | គង់ ពុទ្ធី | ប្រធានលេខាធិការដ្ឋានស្តីទី | គ.ជ.ប.ជ |
| - ឧត្តមសេនីយ៍ត្រី | កែប សារឿន | ប្រធាននាយកដ្ឋាន | គ.ជ.ប.ជ |
| - លោក | តែ សុថារ៉េត | អនុប្រធាននាយកដ្ឋាន | គ.ជ.ប.ជ |
| - លោកស្រី | កែវ ម៉ាលី | អនុប្រធាននាយកដ្ឋាន | ក្រសួងសង្គមកិច្ច |
| - ឧត្តមសេនីយ៍ត្រី | លី សុវិច្ឆ័យ | អនុប្រធាននាយកដ្ឋាន | នា.ប្រឆាំងការជួញដូរមនុស្ស |
| - វរសេនីយ៍ឯក | ឆាន វុធ | នាយការិយាល័យ | នា.ប្រឆាំងការជួញដូរមនុស្ស |
| - អនុសេនីយ៍ឯក | ហ៊ី រតនៈ | នាយរងការិយាល័យ | គ.ជ.ប.ជ |
| - លោក | គង់ វិឡា | អគ្គលេខាធិការ | Cambodia ACTs |